**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ០០៤ សរពក

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ស្ថានភាពក្រោយបទឈប់បាញ់ គិតពីម៉ោង១រសៀល ដល់ម៉ោង៦ល្ងាច ថ្ងៃទី២ ខែមករា ឆ្នាំ២០២៦

**វីរយុទ្ធជនកម្ពុជា និងយោធាថៃ បានបន្តអនុវត្តបទឈប់បាញ់** ធ្វើឱ្យស្ថានភាពស្ងប់ស្ងាត់ ពលរដ្ឋភៀសសឹកបានវិលត្រឡប់ទៅលំនៅឋានវិញជាបណ្តើរៗ ជាពិសេសវីរកងទ័ពទាំង១៨រូប បានធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព ស្របតាមសេចក្តីប្រកាសរួម នៃកិច្ចប្រជុំពិសេសលើកទី៣ គណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC) នៅច្រកព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ **គិតចាប់ពីម៉ោង១រសៀល ដល់ម៉ោង៦ល្ងាច ថ្ងៃទី២ ខែមករា ឆ្នាំ២០២៦**នេះ ស្ថានភាពជារួម មានដូចខាងក្រោម៖

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** មានជនភៀសសឹក**៦៧.០៧៧**នាក់ បានបន្តវិលត្រឡប់ទៅលំនៅឋានវិញ ដែលធ្វើឱ្យជនភៀសសឹកនៅសល់សរុបមានចំនួន ៣២៦.៥៦៣នាក់ ក្នុងនោះស្ត្រី ១៧១.៩៨៧នាក់ និងកុមារ ១០៥.៣៣៣នាក់។

**២-ការបន្តបិទផ្លាក និងការដំណើរការឡើងវិញសេវាសាធារណៈជាមូលដ្ឋាន៖ ខេត្តឧត្តរមានជ័យ** មានសាលារៀន ១០៧ មន្ទីរពេទ្យ/មណ្ឌលសុខភាព១០ រដ្ឋបាលនៅថ្នាក់ខេត្ត១ ក្រុង-ស្រុក២ ឃុំ-សង្កាត់៩ និងប៉ុស្តិ៍នគរបាលរដ្ឋបាល១ បានបន្តបិទផ្លាក ខណៈសាលារៀន១០១ មន្ទីរពេទ្យ/មណ្ឌលសុខភាព៨ រដ្ឋបាលស្រុក៤ អង្គភាពកងកម្លាំងមានសមត្ថកិច្ចថ្នាក់ក្រុង ស្រុក១០ រដ្ឋបាលឃុំ១៨ និងប៉ុស្តិ៍នគរបាលរដ្ឋបាល២៣ បានដំណើរការឡើងវិញ។ **ខេត្តបន្ទាយមានជ័យ** មានសាលារៀន៣២១ (រដ្ឋ២៣៧ ឯកជន៨៤) និងមន្ទីរពេទ្យ/មណ្ឌលសុខភាព៦ បន្តបិទផ្លាក ខណៈសាលារៀន៩ មន្ទីរពេទ្យ/មណ្ឌលសុខភាព១៦ និងរដ្ឋបាលនៅថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ-សង្កាត់ បានដំណើរការឡើងវិញ។ **ខេត្តព្រះវិហារ** មានសាលារៀន៦១ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ នៅបន្តបិទផ្លាក ខណៈរដ្ឋបាលនៅថ្នាក់ស្រុក១ និងឃុំចំនួន៦ បានដំណើរការឡើងវិញ។ ចំពោះ **ខេត្តកោះកុង** មានសាលារៀន៦៦ ដែលបានបិទផ្លាក បានបើកដំណើរការឡើងវិញទាំងអស់។

**៣-ផលប៉ះពាល់ និងការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** គ្មានថ្មី។ ដូច្នេះ បើគិតចាប់ពីថ្ងៃទី៧ ខែធ្នូមក **ការខូចខាតទ្រព្យសម្បត្តិឯកជន** សរុប រួមមាន ផ្ទះ៣២៣ខ្នង អគារស៊ីវិលឯកជន៧ អគារស្នាក់នៅ/សណ្ឋាគារ៥ ស្ថានីយ៍ប្រេង៣ ផ្សារឯកជន១ រថយន្ត៣៣គ្រឿង ម៉ូតូ១គ្រឿង លានទិញដំឡូង១ អគារឃ្លាំងទំនិញ១ បង្គោលអង់តែនទូរសព្ទ២ ជង្រុកស្រូវ១ និងសត្វពាហនៈ/សត្វព្រៃ២ក្បាល។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** សរុបរួមមាន សាលារៀន ១៦ មណ្ឌលសុខភាព៧ សំណង់អគារ៣៩ វត្តអារាម៥ សាលាឆទាន១ រូបសំណាក១ រថយន្ត១គ្រឿង ប្រាសាទបុរាណ៤ ស្ពាន៥ ផ្សារ១ ផ្លូវ៤ និងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី១ទីតាំង។

**៤-កិច្ចអន្តរាគមន៍រៀបចំផ្ទះសំបែង និងភូមិករពលរដ្ឋភៀសសឹក៖ ខេត្តឧត្តរមានជ័យ** មានពលរដ្ឋ២៥.៧១២ គ្រួសារ ស្មើនឹងមនុស្សចំនួន៩៣.៣០៨នាក់ បានវិលចូលរស់នៅក្នុងផ្ទះសំបែងឡើងវិញ មានភូមិចំនួន៨៤ពុំទាន់អាចឱ្យពលរដ្ឋចូលទៅរស់នៅបាន និងភូមិចំនួន១៧២ទៀត ត្រូវបានអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធចុះរៀបចំផ្ទះសំបែងជូនពលរដ្ឋរួចរាល់។ **ខេត្តបន្ទាយមានជ័យ** មានពលរដ្ឋចំនួន៣៥.០៦៧គ្រួសារ ស្មើនឹងមនុស្សចំនួន១១១.៨៥៥នាក់

**ខេត្តព្រះវិហារ** មានពលរដ្ឋ៥.៧៤៦គ្រួសារ ស្មើនឹងមនុស្សចំនួន១៧.៣០៤នាក់ និង**ខេត្តបាត់ដំបង** មានពលរដ្ឋ ២.៩៩០គ្រួសារ បានវិលចូលរស់នៅក្នុងផ្ទះសំបែងឡើងវិញ។ ជារួម **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ-សង្កាត់ បានកំពុងបន្តយកចិត្តទុកដាក់ពិនិត្យ និងដោះស្រាយកិច្ចការអាទិភាពជាច្រើនទៀត ដើម្បីធានាការវិលមករកប្រក្រតីភាព នៃសេវាសាធារណៈជាមូលដ្ឋាននៅតាមបណ្តាក្រុង ស្រុក និងឃុំ-សង្កាត់ ជាពិសេសក្នុងខេត្តជាប់ព្រំដែនដែលបានបិទផ្អាកក្នុងរយៈកាលកន្លងមក។ ជាមួយគ្នានេះ ក៏បាននិងកំពុងខិតខំបង្កលក្ខណៈជូនជនភៀសសឹកឆាប់បានវិលត្រឡប់ទៅលំនៅឋានវិញប្រកបដោយសុវត្ថិភាព។ ក្នុងនោះរួមទាំងការដោះស្រាយបញ្ហាចំពោះមុខសម្រាប់ផ្ទះសំបែង និងភូមិករពលរដ្ឋដែលរងការខូចខាត ការបោសសម្អាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ ទន្ទឹមនឹង**ការពិនិត្យនិងបន្តហាមឃាត់ការបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន)** គ្រប់ទីកន្លែង គ្រប់ពេលវេលា រហូតដល់មានការណែនាំថ្មី។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមគាំទ្រដំហរដ៏មោះមុត និងច្បាស់លាស់របស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ដែលបានគូសបញ្ជាក់ថា **ការអនុវត្តបទឈប់បាញ់ មិនមែនជាការចុះចាញ់ ឬយកបូរណភាពទឹកដី និងអធិបតេយ្យជាតិ ទៅដោះដូរយកសន្តិភាពនោះឡើយ** ដោយសង្កត់ធ្ងន់ថា ខ្សែបន្ទាត់ព្រំដែនអន្តរជាតិរវាងកម្ពុជា-ថៃ នៅតែកំណត់ដោយសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិមានស្រាប់ ដែលកម្ពុជានៅតែរក្សាបានសិទ្ធិពេញលេញក្នុងការដោះស្រាយបញ្ហាព្រំដែនអនុលោមតាមច្បាប់អន្តរជាតិ សន្ធិសញ្ញា អនុសញ្ញា និងយន្តការទ្វេភាគីជាធរមាន ទាំងឡាយ។ សូមជនរួមជាតិ ជឿជាក់លើរាជរដ្ឋាភិបាល ដោយរួបរួមស្មារតីជាតិខ្មែរតែមួយ ចៀសវាងចាញ់ឧបាយកលឃោសនាញុះញង់ពីក្រុមជ្រុលនិយមណាមួយ ធ្វើឱ្យប៉ះពាល់ដល់យុទ្ធសាស្ត្រ «**ស្ងាត់តែមិនស្ងៀម**» ដោយសន្តិវិធី តាមផ្លូវច្បាប់ និងការទូត។ ជាក់ស្តែង យុទ្ធសាស្ត្រ «**ស្ងាត់តែមិនស្ងៀម**» បាននាំមកនូវការធ្វើមាតុភូមិនិវត្តន៍នៃវីរកងទ័ពកម្ពុជាទាំង ១៨រូប ប្រកបដោយមោទកភាព ដែលក្រសួងមហាផ្ទៃមានក្តីស្ងប់ស្ងែងយ៉ាងក្រៃលែងបំផុត ទាំងមាគ៌ាដឹកនាំរបស់រាជរដ្ឋាភិបាល និងសន្ទុះមនសិការជាតិរបស់ប្រជាពលរដ្ឋ ពេលទទួលស្វាគមន៍ដំណើរត្រឡប់របស់វីរកងទ័ព ដូច **សម្តេចតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ក្នុងពិធីជួបសំណេះសំណាលវីរកងទ័ពទាំង១៨រូប នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ អំពីអត្ថន័យកម្លាំងមហាសាមគ្គីជាតិ ដែលកាន់តែផុសខ្ពស់ត្រដែតចេញពីកូនខ្មែរគ្រប់ទិសទី។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមគោរពថ្លែងអំណរគុណ និងគាំទ្រយ៉ាងស្មោះស្ម័គ្រចំពោះ **សម្តេចតេជោ ហ៊ុន សែន** និង **សម្តេចធិបតី ហ៊ុន ម៉ាណែត** ដែលបានដាក់ចេញយុទ្ធសាស្ត្រការពារជាតិយ៉ាងត្រឹមត្រូវ ធ្វើឱ្យប្រជាជនកម្ពុជា ទាំងក្នុង និងក្រៅប្រទេស កាន់តែទទួលបានអារម្មណ៍កក់ក្តៅ ដែលមានប្រតិបត្តិករ គឺវីរយុទ្ធជនជួរមុខឈរជើងយ៉ាងរឹងមាំអង់អាចជាញជ័យ រយៈពេល**២០យប់ ២១ថ្ងៃ** ការពារអធិបតេយ្យជាតិ និងប្រជាជន។ **យើងទាំងអស់គ្នា សូមបន្ទន់កាយ សង្រួមចិត្ត គោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនពលី និងសូមចូលរួមទទួលអារម្មណ៍ឈឺចាប់ និងក្តីមោទនជាមួយក្រុមគ្រួសារ។** យើងក៏សូមជូនពរវីរយុទ្ធជន ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យឆាប់បានជាសះស្បើយ។ សូមជនរួមជាតិ បន្តស្មារតីព្រលឹងខ្មែរតែមួយជានិរន្តរ៍រៀងទៅ។/.

ថ្ងៃសុក្រ ១៤កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០២៦